**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងរដ្ឋប្បវេណីលេខ៖៧៣
ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១
សញ្ញាណនៃរឿងក្តី៖ លែងលះ
សាលក្រមលេខ ៖ ១០(ជ)"១៨៥"
ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០២១

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

- បានបញ្ចប់ធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ២០២១ វេលាម៉ោង ០៩ និង ៣០ នាទីព្រឹក ក្នុងបន្ទប់សវនាការលេខ០២ អគារ ខ នៃសាលាដំបូងខេត្តសៀមរាប ។

- កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ២០២១

**ដោយមានសមាសភាព**

**ចៅក្រម**

-លោក [redacted] អនុប្រធានសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តសៀមរាប

កម្មវត្ថុនៃពាក្យបណ្តឹង : លែងលះប្តី ។

-ភាគីដើមចោទឈ្មោះ [redacted] ឡម ភេទស្រី កើតឆ្នាំ១៩៧៥ ជាតិខ្មែរ មុខរបរគ្រូទាយ អាសយដ្ឋានបច្ចុប្បន្ន[redacted] ឪពុកឈ្មោះ [redacted] ចិន "រស់" ម្តាយឈ្មោះ [redacted]ហ៊ុន "ស្លាប់" ប្តីឈ្មោះ [redacted] ធី មានកូនចំនួន ០៣ នាក់។

អមដោយលោកមេធាវី [redacted]ជាអ្នកតំណាងដោយអាណត្តិភាគីដើមចោទ។

-ភាគីចុងចម្លើយឈ្មោះ [redacted] ធី ភេទប្រុស កើតឆ្នាំ១៩៦៦ ជាតិខ្មែរ មុខរបរមើលកូន អាសយដ្ឋានបច្ចុប្បន្ន[redacted] ឪពុកឈ្មោះ [redacted] អាន "ស្លាប់" ម្តាយឈ្មោះ[redacted]លី "រស់" ប្រពន្ធឈ្មោះ [redacted] ឡម មានកូនចំនួន ០៣ នាក់។

## អង្គហេតុ និងចំណុចវិវាទ

**អង្គហេតុ៖**

ដើមចោទបានរៀបអាពាហ៍ពិពាហ៍ជាមួយ ចុងចម្លើយតាំងពីឆ្នាំ ១៩៩៩ តាមទំនៀមទំលាប់ប្រពៃណីខ្មែរ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ ។ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាមក ការរស់នៅជាមួយគ្នាជាប្តីប្រពន្ធតែងតែមានភាពរកាំរកូសជាញឹកញាប់ ដោយសារចុងចម្លើយមានបានជេរប្រមាថមើលងាយ និងចូលចិត្តប្រច័ណ្ឌទៅលើដើមចោទជាខ្លាំង ។ ក្នុងពេលរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធដើមចោទមានកូនបីនាក់ កូនទី១ឈ្មោះ [redacted] យុទ្ធសាង ភេទប្រុស អាយុ ២១ឆ្នាំ កូនទី២ឈ្មោះ [redacted] យុទ្ធណា ភេទស្រី អាយុ១៩ឆ្នាំ និងកូនទី៣ឈ្មោះ [redacted] ជឹងហ៉រ ភេទប្រុស កើតថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ ។ ចំពោះទ្រព្យសម្បត្តិរួម និងបំណុលដូចមាននៅក្នុងពាក្យបណ្តឹងចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០២១។

ការទាមទាររបស់ដើមចោទ ៖

ដើមចោទប្តឹងសុំឲ្យតុលាការចេញសាលក្រមសម្រេចដូចតទៅ ៖

១-ឱ្យដើមចោទឈប់រស់នៅតាមបែបអនីតិសង្វាសពីចុងចម្លើយឈ្មោះ [redacted]ធី។

២-សុំមានសិទ្ធិអំណាចមេបាលើកូនប្រុសម្នាក់ឈ្មោះ [redacted]ជីងហ័រ កើតនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ ដោយមិនទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូនពីចុងចម្លើយទេ។

៣-សុំបែងចែកទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

៣-១ ឱ្យដើមចោទមានសិទ្ធិកម្មសិទ្ធិតែម្នាក់ឯងលើដី និងផ្ទះមួយល្វែង ជាទ្រព្យសម្បត្តិអវិភាគ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០៦-១២២៦ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ស្ថិតនៅភូមិថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប

៣-២ឱ្យចុងចម្លើយមានកម្មសិទ្ធិតែម្នាក់ឯងលើដី និងផ្ទះមួយកន្លែងដែលជាទ្រព្យអវិភាគ មានបង្កាន់ដៃ ទទួលប្លង់រឹងលេខ ៥៤២៤២៩៥ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ។

៣-៣ ឲ្យចុងចម្លើយទទួលចំណែកពាក់កណ្តាលជាមួយដើមចោទលើដីជាទ្រព្យអវិភាគដែលមានដូចខាងក្រោម៖

ក.ដីស្រែមួយកន្លែងដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ ២០០៧ ទំហំ ៩៨៥៣ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្នល់ដាច់ ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប។

ខ.ដីស្រែមួយកន្លែងដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨ ទំហំ ៩៨៧៨ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្នល់ដាច់ ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប។

គ.ដីដែលមានបង្កាន់ដៃទទួលប្លង់រឹងលេខ ៥៤២៤២៩៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ក្បាលដីលេខ៩៦៥ ស្ថិតនៅភូមិវាល សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ។

ឃ.ដីដែលមានបង្កាន់ដៃទទួលប្លង់រឹងលេខ ៥៤២៦០៤៥ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ក្បាលដីលេខ៩៦៤ ស្ថិតនៅភូមិវាល សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ។

៤-សុំបែងចែកបំណុលរួមឱ្យដើមចោទ និងចុងចម្លើយទទួលបន្ទុកពាក់កណ្តាលម្នាក់ដូច ខាងក្រោម៖

៤-១ បំណុលជំពាក់ធនាគារអេស៊ីលីដា ចំនួន ៥០ ០០០ ដុល្លារអាមេរិក។

៤-២បំណុលជំពាក់ធនាគារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីអង្គរ ចំនួន ១៧០០ដុល្លារអាមេរិក។

៥-សុំបំបែកអនីតិសង្វាសបណ្តោះអាសន្ន ។

៦/ ដើមចោទជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

## សេចក្តីថ្លែងការណ៍របស់ភាគី

### ការអះអាងរបស់ដើមចោទ

- ដើមចោទឈ្មោះ [redacted] ឡុម បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ ខ្លួននិងចុងចម្លើយបានរៀបការជាមួយគ្នាតាំងពីឆ្នាំ១៩៩៩ មកម្លេះ ដោយរៀបការតាមប្រពៃណី និងមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ឡើយ ។ ក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ប្តីខ្លួនតែងតែរករឿងខ្លួនជាប្រចាំ ហើយថែមទាំងជេរប្រមាថមកលើរូបខ្លួនរហូត ។ មិនត្រឹមតែប៉ុណ្ណោះ ការរស់នៅជាមួយ

គ្នាជាប្តីប្រពន្ធមិនដែលមានក្តីសុខឡើយ។ ក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នាខ្លួនមានដីចំនួន ០៤ កន្លែងដោយមានបញ្ជាក់នៅក្នុងសំណុំរឿង ដែលដីទាំងបួនប្លង់នោះខ្លួនបានទិញរួមគ្នាជាមួយចុងចម្លើយ និងស្នើសុំធ្វើការបែងចែកដីទាំងនោះតាមការទាមទារដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ និងដូចក្នុងពាក្យសុំកែតម្រូវកម្មវត្ថុនៃបណ្តឹង ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ដោយស្នើសុំបែងចែដីដែលជាទ្រព្យអវិភាគ មានចំនួន បួនកន្លែង ស្នើសុំធ្វើការបែងចែកដូចខាងក្រោម ៖

ក.ដីស្រែមួយកន្លែងដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ ២០០៧ ទំហំ ៩៨៥៣ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្នល់ដាច់ ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប ប្រគល់ឲ្យមកខ្លួនដែលជាដើមចោទ ។

ខ.ដីស្រែមួយកន្លែងដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨ ទំហំ ៩៨៧៨ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្នល់ដាច់ ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប ប្រគល់ឲ្យទៅភាគី ចុងចម្លើយ ។

គ.ដីដែលមានបង្កាន់ដៃទទួលប្លង់រឹងលេខ ៥៤២៤២៩៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ក្បាលដីលេខ៩៦៥ ស្ថិតនៅភូមិវាល សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ប្រគល់មកឲ្យដើមចោទជាអ្នកគ្រប់គ្រងជាកម្មសិទ្ធិ ។

ឃ.ដីដែលមានបង្កាន់ដៃទទួលប្លង់រឹងលេខ ៥៤២៦០៤៥ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ក្បាលដីលេខ៩៦៤ ស្ថិតនៅភូមិវាល សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ប្រគល់ឲ្យចុងចម្លើយ ។

ចំពោះបំណុលដែលជំពាក់ធនាគារជិតប្រាំម៉ឺនដុល្លារគឺខ្លួនជាអ្នកទទួលរ៉ាប់រងសងតែម្នាក់ឯង។ ដោយឡែកកូនប្រុសម្នាក់ដែលជាអនីតិជនឈ្មោះ [redacted] ជីងហ៊ែរ កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ ខ្លួនជាអ្នកសុំសិទ្ធិជាអ្នកមានអំណាចមេបា ដោយមិនទាមទារអាហារកាតព្វកិច្ចនោះទេ ។

**ការអះអាងរបស់ចុងចម្លើយ**

- ចុងចម្លើយឈ្មោះ [redacted] ធីះ ខ្លួនរស់នៅជាមួយដើមចោទតាំងពីឆ្នាំ១៩៩៩ តែពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ ក្នុងអំឡុងពេលរស់នៅជាមួយគ្នាខ្លួនមិនដែលបានប្រើអំពើហិង្សានៅក្នុងគ្រួសារឡើយ ចំពោះការស្នើសុំលែងលះគឺរូបខ្លួនឯកភាពចំពោះស្នើសុំរបស់ដើមចោទ។

ដោយឡែងចំពោះទ្រព្យសម្បត្តិទាំងអស់គឺជាទព្យសម្បត្តិរួមគ្នាទាំងអស់។ ចំពោះការស្នើសុំបែងចែកដី និងផ្ទះ ដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ និងពាក្យសុំកែតម្រូវកម្មវត្ថុនៃបណ្តឹងចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ គឺរូបខ្ញុំបាទព្រមទទួលយកទាំងអស់ ចំពោះការស្នើសុំបែងចែកដីដែលជាកម្មសិទ្ធិអវិភាគតាមការអះអាងរបស់ភាគីដើមចោទដែលបានអះអាងថា ស្នើសុំបែងចែក ៖ ក.ដីស្រែមួយកន្លែងដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៧ ទំហំ ៩៨៥៣ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្នល់ដាច់ ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប ប្រគល់ឲ្យមកខ្លួនដែលជាដើមចោទ ។

ខ.ដីស្រែមួយកន្លែងដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨ ទំហំ ៩៨៧៨ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្នល់ដាច់ ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប ប្រគល់ឲ្យទៅភាគី ចុងចម្លើយ ។



Scanned with CamScanner

គ.ដីដែលមានបង្កាន់ដៃទទួលប្លង់រឹងលេខ ៥៤២៤២៩៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ក្បាលដីលេខ៩៦៥ ស្ថិតនៅភូមិវាល សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ប្រគល់មកឲ្យដើមចោទជាអ្នកគ្រប់គ្រងជាកម្មសិទ្ធិ ។

ឃ.ដីដែលមានបង្កាន់ដៃទទួលប្លង់រឹងលេខ ៥៤២៦០៤៥ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ក្បាលដីលេខ៩៦៤ ស្ថិតនៅភូមិវាល សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ប្រគល់ឲ្យចុងចម្លើយ ។ គឺខ្លួនឯកភាពតាមការស្នើសុំបែងចែកទាំងអស់ឥតមានការប្រកែកឡើយ។

ចំពោះកូនរូបខ្លួនក៏ព្រមប្រគល់សិទ្ធិអំណាចមេបាឲ្យទៅភាគីដើមចោទផងដែរ ។

**គស្តុតាងសំអាងរបស់ដើមចោទ**

- សំបុត្រកំណើតរបស់ដើមចោទឈ្មោះ [redacted]ឡូម ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥។
- សំបុត្រកំណើតរបស់ដើមចោទឈ្មោះ [redacted]ធី ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៥ ។
- សំបុត្រកំណើតរបស់កូនឈ្មោះ [redacted] ជីងហ័រ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩។

-សៀវភៅស្នាក់នៅ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១១ ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ១៧១០០២០៦-១២២៦ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ។

- បង្កាន់ដៃក្បាលដីលេខ ៥៤២៤២៩៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ។
- បង្កាន់ដៃក្បាលដីលេខ ៥៤២៦០៤៥ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ។
- បង្កាន់ដៃក្បាលដីលេខ ៥៤២៤២៩៥ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ។
- លិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ។
- លិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៧។

**ចំណុចវិវាទ**

គ្មាន ។

**សំអាងហេតុ**

១. ពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃ១៨ ខែកុម្ភៈ ឆ្នាំ២០២១ និងពាក្យសុំកែតម្រូវកម្មវត្ថុពាក្យបណ្តឹង ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ សាលាដំបូងខេត្តសៀមរាបមានសមត្ថកិច្ចអាចទទួលដោះស្រាយ និងវិនិច្ឆ័យបណ្តឹងនេះបានតាមមាត្រា៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២- លិខិតតំណាងដោយអាណត្តិ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ របស់លោកមេធាវី [redacted] ដែលជាអ្នកតំណាងដោយអាណត្តិធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមមាត្រា៥២ មាត្រា៥៣ និងមាត្រា៥៤ ជាអាទិ៍ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៣.ដើមចោទឈ្មោះ [redacted] ឡូម និងចុងចម្លើយឈ្មោះ [redacted] ធី បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងទំនៀមទំលាប់ តែមិនបាន ចុះសំបុត្រអាពាហ៍ពិពាហ៍ឡើយ នេះបញ្ជាក់ថាភាគីដើមចោទនិងចុងចម្លើយមិនទាន់ក្លាយជាសហព័ទ្ធដែលទទួលស្គាល់ដោយច្បាប់ឡើយ ។ តាមការអះអាងរបស់ដើមចោទបានបញ្ជាក់ថាចុងចម្លើយតែងតែរករឿងដល់ដើមចោទ និងបានជេរប្រមាថដល់ដើមចោទ ជាហេតុធ្វើអោយដើមចោទមិនអាចបន្តរួមរស់នៅជាមួយគ្នាជាអនីតិសង្វាសជនតទៅទៀតបានឡើយ



Scanned with CamScanner

ចុងចម្លើយក៏បានឯកភាពផងដែរ។ ឃើញថាដើមចោទអស់មនោសញ្ចេតនាពីចុងចម្លើយ និងពុំមានឆន្ទៈចង់រួមរស់ជាមួយគ្នាបន្តទៅទៀតទេ។ ដើមចោទ និងចុងចម្លើយមានសេរីភាពអាចឈប់រួមរស់ជាមួយគ្នាបានគ្រប់ពេលវេលា ដោយហេតុថាភាគីទាំងពីរពុំមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ឡើយ ហេតុនេះគប្បីតុលាការលើកចោលនូវចំណុចសុំឈប់រស់នៅជាអនីតិសង្វាសរបស់ភាគីដើមចោទ។

៤. នាពេលទាញហេតុផលដោយផ្ទាល់មាត់ ភាគីដើមចោទនិង ភាគីចុងចម្លើយបានព្រមព្រៀងគ្នាចំពោះការបែងចែកទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិអវិភាគរបស់ភាគី និងបំណុលរួមដូចតាមការអះអាងខាងលើហើយភាគីចុងចម្លើយក៏បានយល់ព្រមផ្តល់សិទ្ធិអំណាចមេបាលើកូនប្រុសម្នាក់ឈ្មោះ[redacted]ជីងហ័រ ឲ្យទៅដើមចោទ គប្បីតុលាការសម្រេចតាមការព្រមព្រៀង។

៥. ដើមចោទស្នើសុំសិទ្ធិធ្វើអំណាចមេបាលើកូនប្រុសម្នាក់ឈ្មោះ [redacted] ជីងហ័រ កើតថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ៥៧ សៀវភៅកំណើតលេខ ០១ / ២០០៩ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៩ ។

ឆ្លងតាមការពិនិត្យ ភស្តុតាង ការសាកសួរសាមីភាគីចុងចម្លើយ ឃើញថាកូនទាំងបីនាក់ខាងលើ ពិតជាកូនរបស់ដើមចោទ និងចុងចម្លើយ ហើយបច្ចុប្បន្នកំពុងរស់នៅជាមួយដើមចោទ រីឯភាគីចុងចម្លើយពុំបានយកចិត្តទុកដាក់គ្រប់គ្រងមើលថែរក្សាកូនឡើយ។ ដើមចោទបានបង្ហាញឲ្យឃើញនូវចេតនាល្អ និងឆន្ទៈក្នុងការគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សាកូន និងអប់រំកូន ដែលអាចធានាដល់ឧត្តមប្រយោជន៍សម្រាប់កូន ឃើញថាការទាមទាររបស់ដើមចោទមានលក្ខណៈស្របតាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។

៦. គប្បីតុលាការសម្រេចបន្ថែមអំពីសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនស្របតាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ទោះបីជាគូភាគីពុំបានស្នើសុំក៏ដោយ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១/. លើកចោលនូវការស្នើសុំឈប់រស់នៅជាអនីតិសង្វាសរបស់ភាគីដើមចោទ។

២/. ប្រគល់អំណាចមេបា(សិទ្ធិ និងករណីកិច្ចចិញ្ចឹមកូន) លើកូនប្រុសម្នាក់ ឈ្មោះ[redacted]ជីងហ័រ កើតថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ៥៧ សៀវភៅកំណើតលេខ ០១ /២០០៩ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៩ ឲ្យទៅដើមចោទឈ្មោះ[redacted]ឡុម ។

៣/.បែងចែកទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិអវិភាគរវាងដើមចោទឈ្មោះ[redacted]ឡុម និងចុងចម្លើយឈ្មោះ នូ ធី តាមការព្រមព្រៀងដូចខាងក្រោម៖

៣.១. ប្រគល់ឲ្យទៅភាគីដើមចោទឈ្មោះ [redacted] ឡុម នូវសិទ្ធិកម្មសិទ្ធិលើដី និងផ្ទះដូចខាងក្រោម៖

ក. ដី និងផ្ទះមួយល្វែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០៦-១២២៦ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ស្ថិតនៅភូមិថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

ខ. ដីស្រែមួយកន្លែងដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ ២០០៧ ទំហំ ៩៨៥៣ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្នល់ដាច់ ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប

គ. ដីដែលមានបង្កាន់ដៃទទួលប្លង់រឹងលេខ ៥៤២៤២៩៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ក្បាលដីលេខ៩៦៥ ស្ថិតនៅភូមិវាល សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ។

៣.២. ប្រគល់ឲ្យទៅភាគីចុងចម្លើយឈ្មោះ [redacted]ធី នូវសិទ្ធិកម្មសិទ្ធិលើដី និងផ្ទះដូចខាងក្រោម៖

ក. ដី និងផ្ទះមួយកន្លែងដែលមានបង្កាន់ដៃ ទទួលប្លង់រឹងលេខ ៥៤២៤២៩៥ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ស្ថិតនៅភូមិវាល សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ។

ខ. ដីស្រែមួយកន្លែងដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨ ទំហំ ៩៨៧៨ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្នល់ដាច់ ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប ប្រគល់ឲ្យទៅភាគី ។

គ. ដីដែលមានបង្កាន់ដៃទទួលប្លង់រឹងលេខ ៥៤២៦០៤៥ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ក្បាលដីលេខ៩៦៤ ស្ថិតនៅភូមិវាល សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ។

៤/. បំណុលដែលជំពាក់ធនាគារអេស៊ីលីដា ចំនួន ៥០ ០០០ (ប្រាំម៉ឺន ដុល្លារអាមេរិក)ឲ្យភាគីដើមចោទឈ្មោះ [redacted] ឡុម ជាអ្នកទទួលរ៉ាប់រងសងតែម្នាក់ឯងតាម ការព្រមព្រៀង។

៥/.ឲ្យចុងចម្លើយជាឪពុកមានសិទ្ធិចូលជួបសួរសុខទុក្ខ និងប្រាស្រ័យទាក់ទងជាមួយកូនបានក្នុងមួយសប្តាហ៍ម្តងនៅរៀងរាល់ចុងសប្តាហ៍នីមួយៗ ។ ដើមចោទជាម្តាយត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ទំនាក់ទំនងនេះស្របតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

៦/.ឲ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្តី តាមការស្នើសុំ។

សាលក្រមនេះបានទាញហេតុផល និងប្រកាសជាសាធារណៈ ចំពោះមុខគូភាគី។

**ចៅក្រម**

ហត្ថលេខា និងត្រា ៖ [redacted]

---

ថ្ងៃព្រហស្បតិ៍ ០១រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

សៀមរាបថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២១

**បានឃើញ**
**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]